# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦១ សហវ.នាដ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៥

## ប្រកាស

## ស្តីពី

## ការតម្កល់កិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ និងព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- បានឃើញប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស
- បានឃើញប្រកាសលេខ០៨៣ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ ស្តីពីការណែនាំអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៣ ស្តីពីការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈសំរាប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ អង្គភាពស្វ័យគ្រប់គ្រង
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

## សំរេច:

**ប្រការ ១.-**

អ្នកជាប់ពន្ធដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ ឬកិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ដោយអនុវត្តនូវវិធីសាស្ត្រទិញផ្ទាល់ ចុះកិច្ចសន្យាផ្ទាល់ ស្ទង់តំលៃក្នុងស្រុក ដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើការផ្គត់ផ្គង់ទំនិញ សេវា ជួសជុល និងការសាងសង់គ្រប់ប្រភេទឱ្យដល់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ អង្គភាពស្វ័យគ្រប់គ្រងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ឬសំរាប់អភិវឌ្ឍន៍ឃុំ-សង្កាត់ ត្រូវបំពេញនូវកាតព្វកិច្ចសារពើពន្ធដូចតទៅ :

ក- ចំពោះអ្នកជាប់ពន្ធតាមរបបពិតត្រូវ :

- បង់ពន្ធលើប្រាក់ចំណេញទៅតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណេញ
- បង់អាករលើតំលៃបន្ថែមតាមអត្រា ១០% ដោយយកតំលៃកិច្ចសន្យាចែកនឹង ១១
- បង់ពន្ធលើប្រាក់បៀវត្សតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់បៀវត្ស
- បង់ពន្ធប៉ាតង់ និង
- ពន្ធ-អាករដទៃទៀត តាមការតំរូវនៃច្បាប់ស្តីពីសារពើពន្ធ ។

ខ- ចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវ :

- បង់ពន្ធលើប្រាក់ចំណេញម៉ៅការទៅតាមអត្រា ១% នៃតំលៃកិច្ចសន្យា ។
- បង់អាករលើផលរបរទៅតាមអត្រា ២% នៃតំលៃកិច្ចសន្យា ។

ប្រាក់ពន្ធលើប្រាក់ចំណេញម៉ៅការ និងប្រាក់អាករលើផលរបរដែលត្រូវបង់ គឺយកតំលៃកិច្ចសន្យា គុណនឹង ៣ ហើយចែកនឹង ១០០ ។

- បង់ពន្ធលើប្រាក់បៀវត្សទៅតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់បៀវត្ស
- បង់ពន្ធប៉ាតង់ និង
- ពន្ធ-អាករដទៃទៀត តាមការតំរូវនៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ ២.-**

១- អ្នកជាប់ពន្ធតាមរបបពិតដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវធ្វើការបង់ប្រាក់អាករលើតំលៃបន្ថែម តាមរូបមន្តដូចមានចែងក្នុងប្រការ ១ កថាខ័ណ្ឌ ក ខាងលើ តាមវិធីកាត់ទុកជាមុនពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រង រូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ។

២- អ្នកជាប់ពន្ធតាមរបបម៉ៅការដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវធ្វើការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញម៉ៅការ តាមរូបមន្តដូចមានចែងក្នុងប្រការ ១ កថាខ័ណ្ឌ ខ ខាងលើ ដោយវិធីកាត់ទុកជាមុនពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ។

៣- ក្រៅពីអាករលើតំលៃបន្ថែម (សំរាប់អ្នកជាប់ពន្ធតាមរបបពិត) អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញម៉ៅការ (សំរាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ) ដែលត្រូវបង់តាមវិធីកាត់ទុកពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារ ខេត្ត-ក្រុង អ្នកជាប់ពន្ធត្រូវធ្វើការប្រកាស និងបង់ពន្ធអាករដទៃទៀតនៅអង្គភាពពន្ធដារ ។

៤- ការកាត់ទុកប្រាក់ពន្ធអាករពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ឬរតនាគារខេត្ត-ក្រុង ពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ។ រៀងរាល់ខែ អ្នកជាប់ពន្ធតាមរបបពិតដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និង កិច្ចសន្យាលទ្ធកម្មនៃគំរោងថវិកាវិនិយោគឃុំ-សង្កាត់ ត្រូវដាក់លិខិតប្រកាសអាករលើតំលៃបន្ថែមដោយបញ្ជាក់អំពីអាករលើធាតុចូល អាករលើធាតុចេញ និង ទឹកប្រាក់ត្រូវបង់ទៅតាមសភាពជាក់ស្តែង ។ ប្រសិនបើទឹកប្រាក់អាករដែលបានកាត់ទុកពីអាណត្តិកិច្ចទូទាត់មានចំនួនលើសពីចំនួនទឹកប្រាក់អាករត្រូវបង់ ចំនួនលើសត្រូវបានអនុញ្ញាតជាឥណទានសំរាប់យោងទៅមុខ ឬបង្វិលសង ។

**ប្រការ ៣.-**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ប្រធានរតនាគារខេត្ត-ក្រុង ប្រធានសាខាពន្ធដារខេត្ត-ក្រុង និងប្រធានអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ